## ស្រេចបន្ទាប់

**មាត្រា ១.-** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ហ៊ុយលាំង** (wang huiliang) សញ្ជាតិ ដើម ចិន កើតថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៥៦ នៅទីក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០១

ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

# II- រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

## អនុក្រឹត្យលេខ ៣៣ អ.ន.ក្រ.បក

## ស្តីពីការបង្កើតតំបន់អភិវឌ្ឍន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពីការអនុវត្តន៍គោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី

- ដោយផ្អែកការចាំបាច់នូវការអភិវឌ្ឍន៍តំបន់ជ្រោយចង្វារ

**សំរេច**

**មាត្រា១.~** បង្កើតតំបន់អភិវឌ្ឍន៍ជ្រោយចង្វារលើផ្ទៃដីទំហំ ៤៥០ហិកតានិងមានទីតាំង ស្ថិតនៅចន្លោះផ្លូវជាតិ លេខ ៦អានិងដងទន្លេសាបចាប់ពីគល់ស្ពានជ្រោយចង្វារត្រើយខាង កើត ទៅទិសខាងជើង (ដូចមានផែន ទីភ្ជាប់ ជាមួយ) ។

**មាត្រា២.~** ដីដែលស្ថិតនៅសងខាងគល់ស្ពានជ្រោយចង្វារចំងាយ១០០ម៉ែត្រ អមសងខាងផ្លូវជាតិ លេខ ៦អា ទៅទល់នឹងរង្វង់មូល ត្រូវទុកអោយនៅទំនេរដោយមិនអោយមានសំណង់អ្វីឡើយ ។

**មាត្រា៣.~** ដីក្នុងរង្វង់មូលខាងកើតគល់ស្ពានជ្រោយចង្វារក្នុងរង្វង់កាំចំងាយ១៥០ម៉ែត្រ ត្រូវរក្សាទុកអោយ នៅទំនេរមិនឱ្យមានសំណង់អ្វីឡើយ ។

**មាត្រា៤.~** បណ្តាសំណង់ លំនៅដ្ឋាន ដីធ្លីដែលបានកាន់កាប់កន្លងមកហើយស្ថិតក្នុងតំបន់អភិវឌ្ឍន៍ នេះ រដ្ឋនឹង កំណត់គោលនយោបាយដោះស្រាយ ។

**មាត្រា៥.~** ហាមការជីក និងចាក់បំពេញ ហាមការសាងសង់ថ្មី ការសាងសង់បន្ថែម ការលក់ទិញការផ្ទេរសិទ្ធិ ទាំងអស់នៅក្នុងតំបន់ខាងលើក្រោយពីថ្ងៃចេញអនុក្រឹត្យនេះរហូតដល់មានប្លង់ប្រើប្រាស់ដីធ្លី ។

**មាត្រា៦.~** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងសាធារណការនិងដឹកជញ្ជូនក្រុមប្រឹក្សាអ្នកច្បាប់សាលាក្រុង ៗ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ៣៤ អ.ន.ក្រ.បក

## ស្តីពីការ

## ចេញផ្សាយក្រដាសប្រាក់

## ប្រភេទ ៥០០០រៀល, ១០.០០០រៀល, និង ៥០.០០០រៀល គំរូថ្មី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា